**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសព័ត៌មាន
# លទ្ធផលនៃជំនួបតាមប្រព័ន្ធវីដេអូរវាង
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
# នៃព្រះរាជាណាចក្រកម្ពុជា និង
# ឯកឧត្តម ណារិនដ្រា ម៉ូឌី នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋឥណ្ឌា
# នៅថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២

នៅល្ងាចថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២២ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានជួបតាមប្រព័ន្ធវីដេអូជាមួយ **ឯកឧត្តម ណារិនដ្រា ម៉ូឌី** នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋឥណ្ឌា។

នាយករដ្ឋមន្ត្រីទាំងពីរបានសម្តែងការអបអរសាទរទៅវិញទៅមកក្នុងឱកាសគម្រប់ខួបអនុស្សាវរីយ៍លើកទី៧០ នៃការបង្កើតទំនាក់ទំនងការទូតរវាងកម្ពុជា និងឥណ្ឌា ក្នុងឆ្នាំនេះ។ ជាផ្នែកមួយនៃការគម្រប់ខួបនេះ **ឯកឧត្តម ណារិនដ្រា ម៉ូឌី** បានក្រាបថ្វាយបង្គំយាង **ព្រះករុណា ព្រះបាទ សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង **សម្តេចព្រះមហាក្សត្រី នរោត្តម មុនីនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ** បំពេញព្រះរាជដំណើរទស្សនកិច្ចផ្លូវរដ្ឋ ព្រមទាំងអញ្ជើញ **ឯកឧត្តម ឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត** អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ និងជាមេបញ្ជាការកងទ័ពជើងគោក បំពេញទស្សនកិច្ចផ្លូវការនៅប្រទេសឥណ្ឌា តាមពេលវេលាសមស្រប។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ **ឯកឧត្តម ណារិនដ្រា ម៉ូឌី** និងរដ្ឋាភិបាលឥណ្ឌា ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅប្រទេសឥណ្ឌា ប្រកបដោយប្រសិទ្ធភាព និងជោគជ័យ និងបានសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអំណោយជាវ៉ាក់សាំងកូវីដ-១៩ ប្រភេទកូវីសែល្ឌ ចំនួន ៣២៥.០០០ ដូស ដែលជាជំនួយសប្បុរសធម៌ដ៏ថ្លៃថ្លារបស់ប្រជាជន និងរដ្ឋាភិបាលឥណ្ឌា ក្រោមគំនិតផ្តួចផ្តើមកិច្ចសន្ទនាសន្តិសុខចតុភាគី។ **ឯកឧត្តម ណារិនដ្រា ម៉ូឌី** បានកោតសរសើរចំពោះភាពជោគជ័យរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ នៅកម្ពុជា។

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 21[illegible]
អ៊ីម៉ែល : mfaic@mfaic.gov.kh

ថ្នាក់ដឹកនាំទាំងពីរបានសម្តែងនូវការពេញចិត្តចំពោះទំនាក់ទំនងមិត្តភាពដ៏ស្និទ្ធស្នាល និងកិច្ចសហប្រតិបត្តិការទ្វេភាគីដែលកំពុងរីកចម្រើន រួមមាន ពាណិជ្ជកម្ម និងវិនិយោគ ការអភិវឌ្ឍធនធានមនុស្ស ការពារជាតិ និងសន្តិសុខ កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ការតភ្ជាប់ និងទំនាក់ទំនងរវាងប្រជាជន និងប្រជាជន។ **ឯកឧត្តម ណារិនដ្រា ម៉ូឌី** បានបញ្ជាក់ឡើងវិញនូវការប្តេជ្ញាចិត្តរបស់ឥណ្ឌាចំពោះការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមរបស់កម្ពុជា ដោយចាត់ទុកប្រទេសកម្ពុជាជាផ្នែកដ៏សំខាន់មួយនៃនយោបាយធ្វើសកម្មភាពឆ្ពោះទៅទិសខាងកើតរបស់ឥណ្ឌា ( Act East Policy )។

នាយករដ្ឋមន្ត្រីទាំងពីរបានសម្តែងការពេញចិត្តចំពោះវឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការក្នុងក្របខណ្ឌនៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-ឥណ្ឌា និងកិច្ចសហប្រតិបត្តិការមេគង្គ-គង្គា។ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលឥណ្ឌាដែលបានចូលរួមចំណែកយ៉ាងសកម្មក្នុងតំបន់មេគង្គ និងផ្តល់ជំនួយដល់កម្ពុជាតាមរយៈគម្រោងទទួលផលឆាប់រហ័ស ក្រោមគំនិតផ្តួចផ្តើមកិច្ចសហប្រតិបត្តិការមេគង្គ-គង្គា លើវិស័យកសិកម្ម បរិស្ថាន សុខាភិបាល អភិវឌ្ឍន៍ជនបទ ការអប់រំ ការលើកកម្ពស់ស្ត្រី និងវប្បធម៌។

ថ្នាក់ដឹកនាំទាំងពីរបានផ្លាស់ប្តូរយោបល់គ្នាលើបញ្ហាតំបន់ និងអន្តរជាតិ ដែលជាចំណាប់អារម្មណ៍ និងក្តីកង្វល់រួម រួមមាន បញ្ហានៅមីយ៉ាន់ម៉ា ជម្លោះរវាងអ៊ុយក្រែននិងរុស្ស៊ី បញ្ហាសមុទ្រចិនខាងត្បូង និងទស្សនៈវិស័យអាស៊ានស្តីពីឥណ្ឌូ-ប៉ាស៊ីហ្វិក ។

**ឯកឧត្តម ណារិនដ្រា ម៉ូឌី** បានសម្តែងនូវអំណរសាទរយ៉ាងកក់ក្តៅចំពោះកម្ពុជាក្នុងការចូលកាន់តំណែងជាប្រធានអាស៊ានក្នុងឆ្នាំ២០២២។ **ឯកឧត្តម**បានបញ្ជាក់ជាថ្មីម្តងទៀតនូវការគាំទ្រយ៉ាងពេញទំហឹងរបស់ឥណ្ឌា ចំពោះការធ្វើជាប្រធានអាស៊ានរបស់កម្ពុជាក្នុងឆ្នាំ២០២២ ឱ្យទទួលបានជោគជ័យ។ ជាការឆ្លើយតប **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្រនេះ។

ជាទីបញ្ចប់នៃកិច្ចសន្ទនានេះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានអញ្ជើញ **ឯកឧត្តម ណារិនដ្រា ម៉ូឌី** មកបំពេញទស្សនកិច្ចផ្លូវការនៅកម្ពុជា និងចូលរួមកិច្ចប្រជុំកំពូលអាស៊ាន-ឥណ្ឌា ព្រមទាំងកិច្ចប្រជុំកំពូលពាក់ព័ន្ធផ្សេងទៀត ក្នុងខែវិច្ឆិកា ឆ្នាំ២០២២។ **ឯកឧត្តម ណារិនដ្រា ម៉ូឌី** បានទទួលយកការអញ្ជើញនេះដោយក្តីរីករាយ៕

ថ្ងៃព្រហស្បតិ៍ ៤ រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែឧសភា ឆ្នាំ២០២២